Sacombank

# គោលការណ៍ និងលក្ខខណ្ឌ

## របស់កម្មវិធីប្រូម៉ូសិនជាមួយប័ណ្ណឥណទានវីសា

I. **ផលិតផល៖** ប័ណ្ណឥណទានវីសារបស់ធនាគារសាខម (ខេមបូឌា) ភីអិលស៊ី។

II. **រយៈពេលនៃការអនុវត្ត៖** ចាប់ពីថ្ងៃទី៣ ខែមេសា ឆ្នាំ២០២៣ រហូតដល់ ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២៣។

III. **ព័ត៌មានលម្អិតអំពីកម្មវិធីប្រូម៉ូសិន៖**

<table>
<tr><th>កម្មវត្ថុ</th><th>ការផ្តល់ជូន</th></tr>
<tr><td>អតិថិជនថ្មី</td><td>មិនគិតកម្រៃសេវាសម្រាប់ឆ្នាំដំបូង</td></tr>
<tr><td rowspan="2">គ្រប់ម្ចាស់ប័ណ្ណ</td><td>១. រាល់ការចំណាយយ៉ាងតិច ២០ដុល្លារ,ម្ចាស់ប័ណ្ណនឹងទទួលបាន៖<br><table><tr><td>ទទួលបានប្រាក់សងត្រឡប់មកវិញ ៣ដុល្លារ<br><br>(*)ម្ចាស់ប័ណ្ណម្នាក់ៗអាចទទួលបានប្រាក់សងត្រឡប់មកវិញចំនួន ១ដង នៅតាមពាណិជ្ជករណាមួយ,ហើយអតិបរមាចំនួន ៣ដង នៅពាណិជ្ជករ ៣ផ្សេងៗគ្នាអំឡុងពេលនៃកម្មវិធីប្រូម៉ូសិន។</td><td>១ លេខកូដផ្សងសំណាងដើម្បីឈ្នះរង្វាន់ដ៏មានតម្លៃជាច្រើនក្នុង "កម្មវិធីចាប់រង្វាន់"ដូចជា៖<br><br>• វ៉ាលី ៥០រង្វាន់ មានតម្លៃ ១០០ដុល្លារ<br>• សំបុត្រយន្តហោះ ២រង្វាន់ មានតម្លៃ ១៥០ដុល្លារ<br>• ប័ណ្ណធ្វើដំណើរកំសាន្ត ១រង្វាន់ មានតម្លៃ ៣០០ដុល្លារ<br>[ពិសេស] លេខកូដផ្សងសំណាងចំនួន គុណនឹង២ លើប្រតិបត្តិការដែលបានធ្វើឡើងនៅរៀងរាល់ថ្ងៃសុក្រ និងលេខកូដផ្សងសំណាង គុណនឹង៣ លើប្រតិបត្តិការដែលបានធ្វើឡើងនៅថ្ងៃគម្រប់ខួប ធនាគារសាខម (ខេមបូឌា) ភីអិលស៊ី។ (ថ្ងៃសុក្រទី២៣ ខែមិថុនា ឆ្នាំ២០២៣)។</td></tr></table></td></tr>
<tr><td>២. បញ្ចុះ ៥០% សម្រាប់ថ្លៃសេវាប្តូរទៅគម្រោងបង់រំលស់អត្រាការប្រាក់ 0%</td></tr>
</table>

IV. គោលការណ៍ និងលក្ខខណ្ឌ៖

1- **សម្រាប់អតិថិជនថ្មី៖**

- អតិថិជនថ្មី៖ គឺជាអតិថិជនមិនធ្លាប់មានប័ណ្ណឥណទានវីសារបស់ធនាគារសាខម (ខេមបូឌា) ភីអិលស៊ី ពីមុនមក ឬអតិថិជនដែលធ្លាប់មានប័ណ្ណឥណទានវីសារួចមកហើយតែបានបញ្ឈប់ការប្រើប្រាស់មុនអំឡុងពេលនៃកម្មវិធី ប្រូម៉ូសិន និងចេញប័ណ្ណឱ្យប្រើប្រាស់(Activate) ក្នុងអំឡុងពេល១៥ថ្ងៃ ចាប់ពីថ្ងៃដែលចេញបណ្ណ័។
- សម្រាប់អតិថិជនចាស់ដែលធ្លាប់មានប័ណ្ណឥណទានវីសារបស់ធនាគារសាខម (ខេមបូឌា) ភីអិលស៊ី អាចទទួលបានប្រូម៉ូសិនដូច "អតិថិជនថ្មី" ប្រសិនបើបិទប័ណ្ណមុន ថ្ងៃទី១ ខែកុម្ភៈ ឆ្នាំ២០២៣។
- អតិថិជនថ្មីដែលស្នើសុំប័ណ្ណឥណទានវីសាដែលមានទ្រព្យធានា **(Secure Credit Card)** នឹងមិនគិតកម្រៃសេវា។

2- **កម្មវិធីចាប់រង្វាន់សម្រាប់គ្រប់ម្ចាស់ប័ណ្ណ៖**

**2.1. ទទួលបានប្រាក់សងត្រឡប់មកវិញ ៣ដុល្លារ រាល់ការចំណាយយ៉ាងតិច ២០ដុល្លារ៖**

- ការបញ្ជាទិញដែលគ្រប់លក្ខខណ្ឌ"គឺជាការបញ្ជាទិញក្នុងស្រុក/ឬក្រៅស្រុកតាមរយៈ Online ឬម៉ាស៊ីនឆូតប័ណ្ណដោយប្រើប្រាស់ប័ណ្ណចម្បង និងប័ណ្ណរង ដែលមិនរាប់បញ្ចូលប្រតិបត្តិការដកសាច់ប្រាក់។
- ប្រត្តិបត្តិការដែលបានធ្វើឡើងដោយប័ណ្ណរង នឹងត្រូវកត់ត្រាទុកសម្រាប់ប័ណ្ណចម្បង ។
- ម្ចាស់ប័ណ្ណម្នាក់ៗអាចទទួលបានប្រាក់សងត្រឡប់មកវិញ ចំនួន ១ដង នៅតាមពាណិជ្ជករណាមួយ, ហើយអតិបរមាចំនួន ៣ដង នៅពាណិជ្ជករ ៣ ផ្សេងៗគ្នាអំឡុងពេលនៃកម្មវិធី ប្រូម៉ូសិន។

- ការផ្តល់ជូននេះមានចំនួនកំណត់ អតិថិជនធ្វើប្រតិបត្តិការមុន និងទទួលមុនរហូតដល់គ្រប់ចំនួនដូចបានកំណត់។
- ប្រតិបត្តិការដែលមិនបានបង្ហោះ ឬលុបចោល ឬបង្វិលសងវិញទាំងស្រុង ឬមួយផ្នែកនឹងមិនគ្រប់លក្ខខណ្ឌ ហើយធនាគារសាខម ខេមបូឌា នឹងយកមកវិញដោយកាត់ចេញលើចំនួនប្រាក់សងត្រឡប់មកវិញ ពីប័ណ្ណឥណទានរបស់លោកអ្នក។

**2.2. បញ្ចុះ ៥០% សម្រាប់ថ្លៃសេវាប្តូរទៅគម្រោងបង់រំលស់អត្រាការប្រាក់ 0%**

- ការផ្តល់ជូននេះអនុវត្តចំពោះតែរយៈពេល ០៦ខែ និង ១២ខែ ប៉ុណ្ណោះ។
- ប្រត្តិបត្តិការដែលគ្រប់លក្ខណ្ឌត្រូវតែបំពេញទៅតាមគោលការណ៍ និងលក្ខខណ្ឌរបស់"គម្រោងបង់រំលស់អត្រាការប្រាក់ 0%។

**2.3. កម្មវិធីចាប់រង្វាន់សម្រាប់គ្រប់ម្ចាស់ប័ណ្ណ៖**

**ក. លក្ខខណ្ឌដើម្បីទទួលបានលេខកូដផ្សងសំណាង៖**

- រាល់ការចំណាយយ៉ាងតិច ២០ដុល្លារ នឹងទទួលបានលេខកូដផ្សងសំណាងចំនួន ១ ដើម្បីចូលរួម "កម្មវិធីចាប់រង្វាន់" និងមានឱកាសទទួលបានកាដូជាច្រើនដែលមាព័ត៌មានលម្អិតដូចខាងក្រោម៖

| បញ្ជីឈ្មោះរង្វាន់ | តម្លៃ | ចំនួនរង្វាន់ |
|---|---|---|
| វ៉ាលី | **១០០ដុល្លារ** | ៥០រង្វាន់ |
| សំបុត្រយន្តហោះ | **១៥០ដុល្លារ** | ២រង្វាន់ |
| ប័ណ្ណសម្រាប់ដំណើរកម្សាន្ត | **៣០០ដុល្លារ** | ១រង្វាន់ |

- ពិសេសសម្រាប់ប្រតិបត្តិការគ្រប់លក្ខខណ្ឌដែលបានធ្វើឡើងនៅរៀងរាល់ថ្ងៃសុក្រនឹងទទួលបានលេខកូដផ្សងសំណាង **គុណនឹង២** និងលេខកូដផ្សងសំណាង **គុណនឹង៣** លើប្រតិបត្តិការដែលបានធ្វើឡើងនៅថ្ងៃគម្រប់ខួបរបស់ ធនាគារសាខម (ខេមបូឌា) ភីអិលស៊ី (ថ្ងៃសុក្រទី២៣ ខែមិថុនា ឆ្នាំ២០២៣)។
- រាល់ "ការទិញទំនិញដែលគ្រប់លក្ខខណ្ឌ" មានន័យថាការបញ្ជាទិញទំនិញរាយដែលធ្វើឡើងនៅក្នុងស្រុក និង/ឬនៅក្រៅប្រទេស តាមរយៈម៉ាស៊ីន Online ឬ POS ដោយទាំងប័ណ្ណចម្បង និងប័ណ្ណរង ដែលមិនរាប់បញ្ចូលប្រតិបត្តិការដកសាច់ប្រាក់។
- ប្រត្តិបត្តិការដែលបានធ្វើឡើងដោយប័ណ្ណរង នឹងត្រូវកត់ត្រាទុកសម្រាប់ប័ណ្ណចម្បង ។
- ប័ណ្ណចម្បងអាចទទួលបានរង្វាន់ជាច្រើន ប្រសិនបើជាម្ចាស់ប័ណ្ណមានលេខកូដផ្សងសំណាងកាន់តែច្រើន។
- ប័ណ្ណអំណោយ (Gift Voucher) និងអស់សុពលភាពក្នុងអំឡុងពេល ៩០ថ្ងៃ ចាប់ពីថ្ងៃដែលធនាគារសាខម (ខេមបូឌា) ភីអិលស៊ី បានប្រកាសអំពីអ្នកឈ្នះ។

**ខ. វិធីសាស្ត្រក្នុងការឈ្នះរង្វាន់ពីកម្មវិធីចាប់ឆ្នោតផ្សងសំណាង៖**

- ធនាគារសាខម (ខេមបូឌា) ភីអិលស៊ី នឹងធ្វើការចាប់រង្វាន់ តាមរយៈការផ្សាយបន្តផ្ទាល់អនឡាញ។
- កម្មវិធីចាប់រង្វាន់នឹងផ្សាយផ្ទាល់នៅលើទំព័រ Facebook របស់ធនាគារសាខម ខេមបូឌា។
- កាលបរិច្ឆេទដែលរំពឹងទុកក្នុងការរៀបចំកម្មវិធីចាប់រង្វាន់ដូចខាងក្រោម៖

| សម្រាប់លេខកូដផ្សងសំណាងដែលបានចេញ | កាលបរិច្ឆេទរំពឹងទុក |
|---|---|
| ចាប់ពីថ្ងៃទី៣ ខែមេសា ឆ្នាំ២០២៣ រហូតដល់ ថ្ងៃទី២៦ ខែមិថុនា ឆ្នាំ២០២៣ | ថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០២៣ |

**2.4. ប្រកាសអ្នកឈ្នះរង្វាន់ និងរបៀបប្រើប្រាស់ប័ណ្ណអំណោយ(Gift Voucher)៖**

- **ជំហានទី១៖** ធនាគារសាខម (ខេមបូឌា) ភីអិលស៊ី នឹងទំនាក់ទំនងទៅកាន់អ្នកឈ្នះដើម្បីប្រកាសរង្វាន់ និងប្រាប់អំពីរបៀបដើម្បីប្រើប្រាស់ប័ណ្ណអំណោយ (Gift Voucher)។
- **ជំហានទី២៖** អ្នកឈ្នះត្រូវធ្វើប្រតិបត្តិការជាមួយប័ណ្ណឥណទានវីសា។
- **ជំហានទី៣៖** ហៅមកកាន់ភ្នាក់ងារបម្រើអតិថិជន ០២៣ ២២៣ ៤២៣ និងបញ្ជាក់ការប្រើប្រាស់ប័ណ្ណ ឬចំនួនទឹកប្រាក់។ ធនាគារសាខម ខេមបូឌា នឹងបញ្ជូនទឹកប្រាក់ត្រឡប់ទៅវិញ តាមចំនួនទឹកប្រាក់ចូលទៅក្នុងគណនីប័ណ្ណឥណទាននៅថ្ងៃធ្វើការបន្ទាប់។

## V. លក្ខខណ្ឌផ្សេងទៀត៖

- ប្រតិបត្តិការដែលជោគជ័យ ( ម្ចាស់ប័ណ្ណនឹងទទួលបានសារជូនដំណឹងពីធនាគារ ) ប៉ុន្តែបើក្នុងរយៈពេល៣០ថ្ងៃ ប្រតិបត្តិការទាំងនោះមិនបានកត់ត្រាចូលទៅក្នុងរបាយការណ៍នឹងត្រូវចាត់ទុកជាប្រតិបត្តិការមិនគ្រប់លក្ខខណ្ឌ។
- វិវាទ ការលុបចោល និង/ឬ ប្រតិបត្តិការបរាជ័យក្នុងអំឡុងពេលប្រូម៉ូសិន នឹងត្រូវកាត់ចេញពតម្លៃសរុបនៃប្រតិបត្តិការទិញទំនិញដែលគ្រប់លក្ខខណ្ឌ។
- រាល់ប្រតិបត្តិការដែលមានការសង្ស័យ ឬមិនមានលក្ខខណ្ឌគ្រប់គ្រាន់ដោយផ្អែកលើពេលវេលាទីតាំងរបស់ ប្រតិបត្តិការ ឬកត្តាផ្សេងទៀត នឹងត្រូវកាត់ចេញពីប្រតិបត្តិការដែលមានលក្ខខណ្ឌមុន។ ធនាគារមានសិទ្ធិក្នុងការស្នើសុំអតិថិជន ក្នុងការផ្តល់វិក័យបត្រហិរញ្ញវត្ថុដើម្បីបញ្ជាក់ពីភាពត្រូវត្រឹមត្រូវរបស់ប្រតិបត្តិការ។ ក្នុងករណីដែលអតិថិជនខកខានមិនបានបង្ហាញពីភាពត្រឹមត្រូវរបស់ប្រតិបត្តិការនោះទេនោះធនាគារ នឹងធ្វើការកាត់ចេញតម្លៃសរុបនៃប្រតិបត្តិការទិញទំនិញដែលគ្រប់លក្ខខណ្ឌនោះ។
- ធនាគារសាខម (ខេមបូឌា) ភីអិលស៊ី មានសិទ្ធិបដិសេធនូវរាល់ពាក្យស្នើសុំដែលមិនគ្រប់លក្ខខណ្ឌ មិនច្បាស់លាស់ មិនគ្រប់គ្រាន់ និង/ឬ ឯក សារយោងមិនសមស្រប។

## VI. ពត៌មានបន្ថែម៖

- សម្រាប់ពត៌មានបន្ថែមអតិថិជនអាចអញ្ជើញមកកាន់សាខាណាមួយរបស់ធនាគារសាខម (ខេមបូឌា) ភីអិលស៊ី ឬទំនាក់ទំនងមកកាន់ភ្នាក់ងារបម្រើអតិថិជន៖ ០២៣ ២២៣ ៤២៣ និង ០៩៧៨ ២២៣ ៤២៣។
- ធនាគារសាខម (ខេមបូឌា) ភីអិលស៊ី ទទួលខុសត្រូវ ក្នុងការជូនដំណឹងទៅលើគោលការណ៍ និងលក្ខខណ្ឌនៃកម្មវិធីនេះ និងពត៌មានរបស់អតិថិជនដែលគ្រប់លក្ខខណ្ឌ( រួមមាន ឈ្មោះ លេខអត្តសញ្ញាណប័ណ្ណ/លិខិតឆ្លងដែននិងលេខបួនខ្ទង់ចុងក្រោយរបស់ប័ណ្ណ ចម្បងឥណទាន វីសា) តាមរយៈគេហទំព័ររបស់ធនាគារសាខម ខេមបូឌា៖ sacombank.com.kh ដោយមិនជូនដំណឹងជាមុន។

## VII. លក្ខខណ្ឌទូទៅ៖

- ធនាគារសាខម (ខេមបូឌា) ភីអិលស៊ី មិទទួលខុសត្រូវ ចំពោះការមិនបានជូនដំណឹង ដោយសារបញ្ហាប្រព័ន្ធ Email អាសយដ្ឋាន ឬលេខទូស័ព្ទដែលផ្តល់ដោយម្ចាស់ប័ណ្ណ ឬលិខិតជូនដំណឹងត្រូវបាត់ លួច ឬខូច។
- ធនាគារសាខម (ខេមបូឌា) ភីអិលស៊ី សូមរក្សាសិទ្ធិក្នុងការផ្លាស់ប្តូរលក្ខខណ្ឌទាំងនេះនៅពេលណាមួយដោយមិនចាំបាច់ធ្វើការជូនដំណឹងជាមុន។
- ក្នុងករណីមានវិវាទណាមួយកើតឡើងទាក់ទងនឹងកម្មវិធីប្រូម៉ូសិននេះធនាគារសាខម (ខេមបូឌា) ភីអិលស៊ី និងដោះស្រាយវិវាទនេះយ៉ាងសមស្របបំផុតទៅកាន់អតិថិជនប្រសិនបើបរាជ័យក្នុងការដោះស្រាយវិវាទនោះ នឹងត្រូវបានដោះស្រាយទៅតាមផ្លូវច្បាប់ដែលបានកំណត់។
- តាមរយៈការចូលរួមក្នុងកម្មវិធីនេះ គ្រប់ម្ចាស់ប័ណ្ណទាំងអស់ ត្រូវចាត់ទុកថាទទួលនិងយល់ព្រមនូវគោលការណ៍ និងលក្ខខណ្ឌរបស់កម្មវិធី។